ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

Australian Aid



# គម្រោង
# បញ្ចប់អំពើហិង្សា
# លើស្ត្រីនៅកម្ពុជា
# (EVAW Program)

របាយការណ៍វឌ្ឍនភាពលើកទី៣
ខែកក្កដា ឆ្នាំ២០១៧



*សមាជិកក្រុមជួយខ្លួនឯង កម្មវិធីរបស់អង្គការចិត្តសង្គម អន្តរវប្បធម៌ ខេត្តបាត់ដំបង*

Australian Aid

The Asia Foundation

ACTED

HAGAR

Services provided by Coffey International Development on behalf of DFAT.

# មាតិកា

២ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា
៤ ភាពជាដៃគូនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា ឆ្នាំ២០១២-២០១៧
៧ វិសាលភាពនៃសកម្មភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា
៩ យុទ្ធនាការសាធារណៈថ្នាក់ជាតិ
១០ វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការផ្តល់សេវា
១២ វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការទប់ស្កាត់
១៤ វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការការពារផ្នែកច្បាប់
១៦ វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការគាំទ្រស្ថាប័ន និងការសម្របសម្រួល
១៨ វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការសិក្សាស្រាវជ្រាវ និងភស្តុតាង
១៩ ករណីសិក្សា

## កំណត់សម្គាល់ អំពីទិន្នន័យ

ទិន្នន័យនៅក្នុងរបាយការណ៍នេះត្រូវបានប្រមូលចងក្រងពីគ្រប់ដៃគូដែលបានអនុវត្តសកម្មភាពកម្មវិធីចាប់ពីខែមករា ឆ្នាំ២០១៣ ដល់ ខែមិថុនា ឆ្នាំ២០១៧។

លទ្ធផល និងសមិទ្ធិផលសម្រេចបាននៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជាត្រូវបានវាស់វែង និងរាយការណ៍ដោយសូចនាករបែបបរិមាណ និងគុណភាព ដើម្បីបង្ហាញអំពីទិដ្ឋភាពរួមរបស់គម្រោងទាំងមូល។ សូចនាករជាច្រើនដូចជាទិន្នន័យអំពីប្រសិទ្ធភាពការងារ ទិន្នន័យយេនឌ័រ ករណីសិក្សា និងការបង្ហាញរូបថតនៃសកម្មភាពរបស់កម្មវិធី។

ព័ត៌មាននៅក្នុងរបាយការណ៍នេះត្រូវបានផ្តល់ដោយដៃគូអនុវត្តគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា។ ទិន្នន័យនេះត្រូវបានប្រមូលចងក្រងផ្អែកលើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ឆមាស និងត្រីមាស។

កម្មវិធីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់បានទទួលមូលនិធិគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃប្រទេសអូស្ត្រាលី និងក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) នៃរដ្ឋាភិបាលអាល្លឺម៉ង់។

រាល់ទិន្នន័យរបស់អង្គការសហប្រតិបត្តិការអាល្លឺម៉ង់ត្រូវបានបែងចែកជាសមាមាត្រនៃសកម្មភាពដែលត្រូវបានផ្តល់មូលនិធិដោយក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃប្រទេសអូស្ត្រាលី។

អ្នកចូលរួមក្នុងករណីសិក្សាបានអនុញ្ញាតឱ្យយើងប្រើឈ្មោះពិតរបស់ខ្លួននៅក្នុងរបាយការណ៍នេះ។ ក្នុងករណីគ្មានការអនុញ្ញាត ឈ្មោះរបស់អ្នកចូលរួមត្រូវបានដូរដើម្បីការពារអត្តសញ្ញាណរបស់ពួកគេ។

រូបថតត្រូវបានផ្តល់ដោយដៃគូអនុវត្ត និងទទួលបានការអនុញ្ញាឱ្យប្រើប្រាស់នៅក្នុងរបាយការណ៍នេះ។

# គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា (EVAW Program)

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជាត្រូវបានអនុវត្តរួមគ្នាដោយក្រសួងកិច្ចការនារី (MOWA) នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃរដ្ឋាភិបាលអូស្ត្រាលី។ នេះជាគម្រោងភាពជាដៃគូរយៈពេលប្រាំឆ្នាំដែលបានចាប់ផ្តើម ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៧។ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីមានគោលបំណងផ្តល់ការគាំទ្រដល់ក្រសួងកិច្ចការនារីលើការរៀបចំ និងការអនុវត្ត ការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី (VAW) នៅកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានប្តេជ្ញាចិត្តដោះស្រាយអំពើហិង្សាលើស្ត្រីតាមរយៈការផ្តល់សច្ចាប័ន និងការអនុវត្តច្បាប់ និងគំនិតផ្តួចផ្តើមគោលនយោបាយដែលផ្តោតជាពិសេសលើការកាត់បន្ថយអំពើហិង្សាលើស្ត្រី និងកុមារី និងលើកទឹកចិត្តស្ត្រីចូលរួមបានពេញលេញក្នុងជីវិតសាធារណៈ។ ក្រសួងកិច្ចការនារីជាស្ថាប័នជាតិដែលទទួលខុសត្រូវលើការលើកកម្ពស់ឋានៈ តួនាទីស្ត្រី និងសម្រេចបានលទ្ធផលលើការងារតាមរយៈអ្នកដឹកនាំ ការសម្របសម្រួល និងការបញ្ចូលសមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ ក្រសួងកិច្ចការនារីដឹកនាំការអនុវត្ត និងការពិនិត្យតាមដានគំនិតផ្តួចផ្តើមគោលនយោបាយសំខាន់ៗពីរ។

❖ ***ផែនការនារីរតនៈទី៤ ឆ្នាំ២០១៤-២០១៨*** ជាផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំសម្រាប់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី។ ផែនការនេះរួមចំណែកការអនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការលើកកម្ពស់តួនាទីរបស់ក្រសួងកិច្ចការនារី ក្នុងការវិភាគយេនឌ័រ ការតស៊ូមតិផ្នែកស្ថាប័ន និងប្រឹក្សាយោបល់លើគោលនយោបាយប្រកបដោយប្រសិទ្ធភាពដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅក្នុងរាជរដ្ឋាភិបាលទាំងមូល។

❖ ***ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៤-២០១៨*** (NAPVAW) ជាគោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តអភិក្រមទូទាំងរដ្ឋាភិបាលសម្រាប់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងខែធ្នូ ឆ្នាំ២០១៤ និងដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ស្ថាប័នជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិអនុវត្តរួមគ្នាដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផ្តល់កិច្ចការពារដល់ជនរងគ្រោះដោយអំពើហិង្សា។

“ទោះបីជាក្រសួងកិច្ចការនារីជាស្ថាប័នដឹកនាំគាំទ្រក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីក៏ដោយ ប៉ុន្តែជាក់ស្តែង គ្មានក្រសួង មន្ទីរ ឬអង្គការណាមួយអាចកាត់បន្ថយអំពើហិង្សាលើស្ត្រីតែឯងបានទេ។”

លោកជំទាវ វេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី**
រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
ឆ្នាំ២០១៤



ជំនួយអូស្ត្រាលីឆ្នាំ២០១៤៖ គោលនយោបាយអភិវឌ្ឍន៍ដែលលើកកម្ពស់វិបុលភាព កាត់បន្ថយភាពក្រីក្រ ពង្រឹងស្ថេរភាព លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី និងកុមារីតាមរយៈអភិក្រមក្នុងការ

- បង្កើនសម្លេងស្ត្រីក្នុងការធ្វើសេចក្ដីសម្រេច ភាពជាអ្នកដឹកនាំ និងការកសាងសន្តិភាព
- លើកកម្ពស់ការពង្រឹងភាពអង់អាចដល់ស្ត្រី និង
- បញ្ចប់អំពើហិង្សាលើស្ត្រី

គោលនយោបាយនេះទទួលស្គាល់ថា ភាពជាអ្នកដឹកនាំ ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច និងសេរីភាពរបស់ស្ត្រីអំពីអំពើហិង្សាមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

> “ដំណោះស្រាយរយៈពេលវែងសម្រាប់អំពើហិង្សាលើស្ត្រី គឺការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ នៅពេលដែលយើងពង្រឹងភាពអង់អាចដល់ស្ត្រី យើងពង្រឹងភាពអង់អាចដល់គ្រួសាររបស់ស្ត្រី យើងពង្រឹងភាពអង់អាចដល់សហគមន៍របស់ស្ត្រី យើងពង្រឹងភាពអង់អាចដល់សង្គមរបស់ស្ត្រី និងយើងពង្រឹងភាពអង់អាចដល់ប្រទេសរបស់ស្ត្រី។”
>
> រដ្ឋមន្ត្រីទទួលបន្ទុកការអភិវឌ្ឍន៍អន្តរជាតិ និងប៉ាស៊ីហ្វិក សមាជិកព្រឹទ្ធសភា លោកស្រី **ខន់សិត្តា ហ្វៀរ៉ាវ៉ាន់ធិ វ៉ែល** (Senator Concetta Fierravanti-Wells) ឆ្នាំ ២០១៧

## គំរូនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី

**គោលដៅនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី**

ការកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅកម្ពុជាប្រកបដោយចីរភាព

**គោលបំណងនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី**

រួមចំណែកការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព ជាលក្ខណៈប្រព័ន្ធ និងប្រកបដោយគណនេយ្យភាព

**យុទ្ធសាស្ត្រសំខាន់ៗបី**

| ការផ្ដល់សេវា | ការទប់ស្កាត់ | ការការពារផ្នែកច្បាប់ |
|---|---|---|
| ការផ្ដល់សេវាដែលសមស្រប និងប្រកបដោយគុណភាពដល់ជនរងគ្រោះនៅកន្លែងដែលពួកគេស្វែងរកជំនួយរាប់បញ្ចូលទាំងជម្រើសផ្សេងៗសម្រាប់សេវាបញ្ជូន | យុទ្ធសាស្ត្រត្រូវបង្កើតឡើងដើម្បីជំរុញការផ្លាស់ប្ដូរជាវិជ្ជមានលើទស្សនៈយល់ឃើញ ឥរិយាបថ អាកប្បកិរិយា ជំនឿ ការអនុវត្តន៍ និងបទដ្ឋានសង្គម | ការស៊ើបអង្កេតដើម្បីការពារ និងដំណើរការផ្លូវច្បាប់ដែលមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ប្រព្រឹត្តលើជនរងគ្រោះដោយអំពើហិង្សាដោយសេចក្ដីថ្លៃថ្នូរនិងតម្រូវឱ្យជនល្មើសទទួលខុសត្រូវចំពោះមុខច្បាប់ |

**យុទ្ធសាស្ត្រសំខាន់ៗពីរផ្សេងទៀត**

| ការគាំទ្រស្ថាប័ន និងការសម្របសម្រួល | ការសិក្សាស្រាវជ្រាវ និងភស្តុតាង |
|---|---|
| ធ្វើការជាមួយរាជរដ្ឋាភិបាល ផ្នែកឯកជន និងសង្គមស៊ីវិលក្នុងការកែលម្អការគាំទ្រ និងការសម្របសម្រួលការឆ្លើយតបដល់ជនរងគ្រោះដោយអំពើហិង្សា | ជំរុញឱ្យមានការប្រើប្រាស់ព័ត៌មានស្រាវជ្រាវ និងភស្តុតាងសម្រាប់ការកែលម្អផែនការ ការផ្ដល់សេវា និងការអនុវត្តសេវាគាំទ្រ |

# ដៃគូអនុវត្តគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីឆ្នាំ ២០១២-២០១៧

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីផ្ដល់នូវចំណុចខ្លាំង ចំណេះដឹង និងជំនាញដល់ដៃគូរបស់ខ្លួនក្នុងការផ្ដល់សេវា។ គម្រោងនេះមានដៃគូជាមន្ត្រីជាន់ខ្ពស់នៃក្រសួងកិច្ចការនារី តំណាងក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី ព្រមទាំងអង្គការជាតិ និងអន្តរជាតិ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅកម្ពុជា និងមានបទពិសោធន៍ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)។

ភាពជាដៃគូបានជំរុញឱ្យមានការផ្សាភ្ជាប់ទំនាក់ទំនងកាន់តែទូលំទូលាយរវាងកម្មវិធីផ្សេងៗ ដែលជួយបំពេញបន្ថែមកាន់តែប្រសើរឡើងលើការអនុវត្តគម្រោងសម្រាប់ជនរងគ្រោះដោយអំពើហិង្សា និងបង្កើនទំនាក់ទំនង និងសហប្រតិបត្តិការក្នុងចំណោមដៃគូអនុវត្តទាំងអស់។

ការចូលរួមដ៏សកម្មពីតំណាងជាន់ខ្ពស់របស់ក្រសួងកិច្ចការនារី បានផ្ដល់ការគាំទ្រយ៉ាងច្រើនដល់ការអនុវត្តសកម្មភាពនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីតាមរយៈការផ្ដល់យោបល់ជាយុទ្ធសាស្ត្រ និងពិធីការ ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងគោលការណ៍ណែនាំ និងផ្ដល់លទ្ធភាពដល់ក្រសួងពាក់ព័ន្ធដទៃទៀត និងអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការចូលរួមឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើហិង្សា។

| ឆ្នាំ | ស្ថាប័ន/អង្គការដៃគូ | ការពិពណ៌នាកម្មវិធី |
| --- | --- | --- |
| ២០១២ | អង្គការសហប្រជាជាតិសម្រាប់សមធម៌យេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី (UN Women) | **ខែឧសភា ឆ្នាំ២០១២ - ខែធ្នូ ឆ្នាំ២០១៥**<br>រៀបចំផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ឆ្នាំ២០១៤ - ២០១៨។ អនុវត្តការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្ដីពីប្រវ៉ាឡង់អំពើហិង្សាលើស្ត្រី (ការសិក្សាស្រាវជ្រាវស្ដីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅកម្ពុជា) ដើម្បីជាមូលដ្ឋានសម្រាប់ការទប់ស្កាត់ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី។ |
| ២០១៣ | អង្គការ ហាហ្គា (Hagar) | **ខែមីនា ឆ្នាំ២០១៣ - ខែមិថុនា ឆ្នាំ២០១៧**<br>ផ្ដល់ជំនួយ និងកម្មវិធីថែទាំសម្រាប់ស្ត្រី និងកុមារដែលរងគ្រោះដោយអំពើហិង្សា និងការជួញដូរមនុស្ស អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភសិទ្ធិមនុស្ស។ កម្មវិធីអន្តរាគមន៍ផ្ដោតលើការកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តផ្ទាល់ខ្លួន លទ្ធភាពការងារធ្វើ និងការថែរក្សាការងារ ការទទួលបានការអប់រំ និងសមាហរណកម្មក្នុងគ្រួសារ និងសហគមន៍។ |
| | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) | **ខែមីនា ឆ្នាំ២០១៣ - ខែមិថុនា ឆ្នាំ២០១៧**<br>ពង្រឹងយន្តការឆ្លើយតបផ្លូវច្បាប់ និងប្រព័ន្ធយុត្តិធម៌ក្នុងការឆ្លើយតបទៅនឹងបទល្មើសអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសរំលោភបំពានផ្លូវភេទ។ ផ្ដល់យោបល់ និងការគាំទ្រផ្លូវច្បាប់តាមរយៈប្រព័ន្ធតុលាការដល់ស្ត្រី និងកុមារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ។ |
| | អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) | **ខែមីនា ឆ្នាំ២០១៣ - ខែមិថុនា ឆ្នាំ២០១៧**<br>លើកកម្ពស់សមភាពយេនឌ័រ និងការទទួលបានសេវាចិត្តសង្គមដែលបានកែលម្អសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងការរំលោភបំពានផ្លូវភេទ (SA) តាមរយៈការផ្ដល់ប្រឹក្សាក្រុមជួយខ្លួនឯង និងបណ្ដាញគាំទ្រសហគមន៍។ |
| | ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស និងអភិវឌ្ឍន៍ (ACTED) | **ខែមេសា ឆ្នាំ២០១៣ - ខែមិថុនា ឆ្នាំ២០១៧**<br>អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភផ្លូវភេទលើស្ត្រីបម្រើសេវាកំសាន្តនៅរាជធានីភ្នំពេញត្រូវបានកាត់បន្ថយតាមរយៈកម្មវិធីមិត្តអប់រំមិត្តសម្រាប់ស្ត្រី និងអ្នកឧបត្ថម្ភ ដើម្បីលើកកម្ពស់ការផ្លាស់ប្ដូរអាកប្បកិរិយា និងឥរិយាបថ។ ផ្ដល់ការបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងដល់នគរបាលឃុំ/សង្កាត់ ដើម្បីបង្កើនការរាយការណ៍អំពីសកម្មភាពអំពើហិង្សា។ ACTED ធ្វើការជាដៃគូជាមួយអង្គការសេវាសង្គមកិច្ចកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ |
| | ទីប្រឹក្សាបច្ចេកទេសយេនឌ័រ (Gender Consultant) | ឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាលើកទី៣ (CGA) ឆ្នាំ ២០១៤ ដែលជាឯកសារវិភាគនៃសេចក្ដីសង្ខេបគោលនយោយចំនួន១០ ត្រូវបានពិនិត្យស្របគ្នាជាមួយនារីរតនទី៤។ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានគាំទ្រការរៀបចំសេចក្ដីសង្ខេបគោលនយោបាយជំពូកទី៧៖ អំពើហិង្សាលើស្ត្រី និងកុមារី។ |

| | | |
|---|---|---|
| | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) | **ខែវិច្ឆិកា ឆ្នាំ២០១៣ - ខែធ្នូ ឆ្នាំ២០១៥**<br>ការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យដើម្បីធានានូវការបញ្ចូលទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រីជាប្រធានបទស្នូលនៅក្នុងរបាយការណ៍អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០១៤។ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានគាំទ្រជំពូកទី២០៖ អំពើហិង្សាក្នុងគ្រួសារ។ |
| | អង្គការមូលនិធិអាស៊ី (TAF) | ឯកសារស្តីពីបញ្ហាប្រលម (Issues Paper)៖ ការវិភាគសេដ្ឋកិច្ចនយោបាយអំពីការអនុវត្តច្បាប់ដែលឆ្លើយតបនឹងគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំធ្វើឡើងដើម្បីទទួលបានព័ត៌មានកាន់តែច្បាស់សម្រាប់ការអនុវត្តគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី។ |
| ២០១៤ | អង្គការសហប្រជាជាតិសម្រាប់សមធម៌យេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី (UN Women) | **ខែឧសភា ឆ្នាំ២០១៤ - ខែធ្នូ ឆ្នាំ២០១៥**<br>ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស សហប្រជាជាតិសម្រាប់សមធម៌យេនឌ័រនិងការពង្រឹងភាពអង់អាចដល់ស្ត្រីដល់ក្រសួងកិច្ចការនារី ក្នុងការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ដែលជាស្ថាប័នទទួលខុសត្រូវលើការធានានូវការពិនិត្យតាមដាន ការរាយការណ៍ និងការសម្របសម្រួលផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ |
| | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) | **ខែឧសភា ឆ្នាំ២០១៤ - ខែមិថុនា ឆ្នាំ២០១៧**<br>បង្កើនការទទួលបានសេវា និងគុណភាពសេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រជាពិសេសអំពើហិង្សាផ្លូវកាយ និងផ្លូវភេទតាមរយៈការបង្កើតប្រព័ន្ធបញ្ជូនដែលមានដំណើរការ និងការរៀបចំ និងអនុវត្តប្រព័ន្ធប្រមូល និងវិភាគទិន្នន័យ។ សកម្មភាពនេះរួមមានការអភិវឌ្ឍន៍សមត្ថភាព និងការបណ្តុះបណ្តាលផ្នែកច្បាប់ដល់មន្ត្រីនគរបាលយុត្តិធម៌ក្រសួងកិច្ចការនារី (JPO) ជាសមាជិកដ៏សំខាន់នៃបណ្តាញបញ្ជូនករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ GIZ បានធ្វើការជាដៃគូជាមួយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) និងអង្គការបន្ទាយស្រី។ |
| | អង្គការមូលនិធិអាស៊ី (TAF) | **ខែមីនា ឆ្នាំ២០១៤ - ខែមីនា ឆ្នាំ២០១៥**<br>កម្មវិធីសិក្សាស្រាវជ្រាវត្រូវបានអនុវត្តដើម្បីកំណត់កត្តាគ្រោះថ្នាក់ និងកត្តាការពារក្នុងការទប់ស្កាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល (IPV)។ កម្មវិធីបានរៀបចំឯកសារស្រាវជ្រាវចំនួន៤ជាបន្តបន្ទាប់ ឯកសារសង្ខេបស្តីពីការកំណត់គោលដៅអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ |
| ២០១៥ | អង្គការមូលនិធិអាស៊ី (TAF ) | **ខែមីនា ឆ្នាំ២០១៥ - ខែសីហា ឆ្នាំ២០១៧**<br>ដោយប្រើប្រាស់ការសិក្សាស្រាវជ្រាវដែលបានធ្វើ កម្មវិធីទប់ស្កាត់អំពើហិង្សាដលើដៃគូស្និទ្ធស្នាល (PIPV) បានរៀបចំ និងអនុវត្តអន្តរាគមន៍ក្នុងសហគមន៍ ដើម្បីកាត់បន្ថយការប្រើប្រាស់បំពានគ្រឿងស្រវឹង និងអំពើហិង្សាលើដៃគូស្និទ្ធស្នាល។ ក្នុងភាពជាដៃគូជាមួយតំណាងរាជរដ្ឋាភិបាល និងតំណាងក្រុមហ៊ុនផលិតគ្រឿងស្រវឹង កម្មវិធីបានពិចារណាលើជំពឹស ក្នុងការកាត់បន្ថយខ្លឹមសារនៃការផ្សព្វផ្សាយតាមទូរទស្សន៍ដែលបណ្តោយឱ្យមានអំពើហិង្សាលើស្ត្រី។ អង្គការមូលនិធិអាស៊ីបានបំពេញការងារជាដៃគូជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) វិទ្យាស្ថានបើកទូលាយ (Open Institute) អង្គការពន្លឺកុមារកម្ពុជា និងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព។ |
| ២០១៦ | អង្គការសហប្រជាជាតិសម្រាប់សមធម៌យេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី (UN Women ) | **ខែកុម្ភៈ ឆ្នាំ២០១៦ - ខែសីហា ឆ្នាំ ២០១៧**<br>ផ្តល់ការគាំទ្រដល់ក្រសួងកិច្ចការនារី និងក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រដើម្បីជំរុញ និងពន្លឿនការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីតាមរយៈការជំរុញឱ្យមានការចូលរួមពីអ្នកធ្វើគោលនយោបាយជាតិ និងបង្កើនការចិត្តទុកដាក់លើការជំរុញការចូលរួមរបស់មន្ត្រីជាដៃគូនៅថ្នាក់ក្រោមជាតិ។ |
| | អង្គការ ឃែរ (CARE) | **ខែមករា ឆ្នាំ២០១៦ - ខែសីហា ឆ្នាំ២០១៧**<br>កម្មវិធីផ្ទះមានសុវត្ថិភាព សហគមន៍មានសុវត្ថិភាពបានជំរុញឱ្យមានការចូលរួមពីអ្នកផ្តល់សេវាថែទាំសុខភាពអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីបង្កើនការយល់ដឹង និងកែលម្អការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនៅក្នុងសហគមន៍។ |
| | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA ) | **ខែឧសភា ឆ្នាំ២០១៦ - ខែសីហា ឆ្នាំ២០១៧**<br>ផ្តល់ការគាំទ្របច្ចេកទេសដល់ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល (MOH) ក្នុងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្របណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់វិស័យសុខាភិបាលដែលឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងកុមារី និងធ្វើការវិភាគទិន្នន័យដែលមានស្រាប់នៃអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤ ដើម្បីពិនិត្យលើនិន្នាការអំពើហិង្សាក្នុងពេលកន្លងមក។ |

## សកម្មភាពចូលរួមក្នុងគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីតាមយុទ្ធសាស្ត្រនីមួយៗ




**៧** — អង្គការអន្តរជាតិ

**៨** — អង្គការជាតិ

**១៥** — សរុបភ្នាក់ងារអនុវត្ត

## កត្តាជោគជ័យសំខាន់ៗ

- បរិយាកាសអំណោយផលសម្រាប់ដៃគូទាំងអស់ក្នុងការចែករំលែកបទពិសោធន៍ និងរៀនសូត្រពីគ្នា។
- ការកើនឡើងលទ្ធភាពក្នុងជួបពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។
- ការកើនឡើងនៃទំនាក់ទំនង និងសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការផ្តល់សេវាកាន់តែប្រសើរឡើង។



*ដៃគូអនុវត្តគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា*

# វិសាលភាពនៃសកម្មភាពរបស់គម្រោង

ការឆ្លើយតបទៅនឹងបញ្ហាអំពើហិង្សាលើស្ត្រីមានភាពស្មុគស្មាញខ្លាំង និងទាមទារឱ្យមានការឆ្លើយតប និងអន្តរាគមន៍ផ្សេងៗគ្នា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានផ្តល់ការគាំទ្រលើសកម្មភាពការងារជាច្រើនដែលត្រូវបានអនុវត្តជាសាកល។ ការគាំទ្រនេះរួមមានការបង្កើត និងអនុវត្តគោលនយោបាយជាតិ កម្មវិធីបណ្តុះបណ្តាល ការបង្វឹកគ្រូបណ្តុះបណ្តាល ប្រព័ន្ធត្រួតពិនិត្យតាមដាន និងប្រមូលទិន្នន័យ ការបង្កើតគោលការណ៍ណែនាំ និងការសម្របសម្រួល ការប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ពីសំណាក់អ្នកផ្តល់សេវានានា។

**១៨**
ចំនួនរាជធានី /ខេត្ត

**៦៦**
ចំនួនក្រុង/ស្រុក/ខណ្ឌ

**៥៣៨**
ចំនួនឃុំ/សង្កាត់

## វិសាលភាពនៃសកម្មភាពរបស់គម្រោងចាប់ពីខែមករា ឆ្នាំ២០១៣ ដល់ខែមិថុនា ឆ្នាំ២០១៧

| ភ្នាក់ងារអនុវត្ត | រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ |
|---|---|---|---|
| **ឆ្នាំ២០១៣** | | | |
| TPO | 1 | 1 | 3 |
| LAC | 2 | 6 | 45 |
| ACTED | 1 | 4 | 25 |
| Hagar | អង្គការហាហ្គាធ្វើការជាមួយអតិថិជនម្នាក់ៗតាមរយៈគំរូនៃការគ្រប់គ្រងករណី ។ ក្នុងអំឡុងពេលអនុវត្តគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី សេវាត្រូវបានផ្តល់ជូនអតិថិជន។ | | |
| **ឆ្នាំ២០១៤** | | | |
| GIZ | 2 | 20 | 181 |
| **ឆ្នាំ២០១៥** | | | |
| TAF | 2 | 4 | 19 |
| **ឆ្នាំ២០១៦** | | | |
| CARE | 1 | 4 | 19 |
| TAF | 2 | 4 | 30 |
| UN Women | 2 | 4 | 27 |
| UNFPA | 9 | 23 | 194 |
| **ឆ្នាំ២០១៧** | | | |
| TAF | 2 | 4 | 47 |
| CARE | 2 | 5 | 30 |

## កត្តាជោគជ័យសំខាន់ៗ

- មានការយកចិត្តទុកដាក់កាន់តែប្រសើរឡើងលើការអនុវត្តសកម្មភាពនៅថ្នាក់ក្រោមជាតិ
- មានការចូលរួមកាន់តែច្រើនពីសំណាក់អាជ្ញាធរថ្នាក់ក្រោមជាតិដូចជា គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត និងក្រុង/ស្រុក/ខណ្ឌ គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ ចៅសង្កាត់ មេឃុំ និងមេភូមិ និងតំណាងរាជរដ្ឋាភិបាលថ្នាក់រាជធានី/ខេត្ត
- មានទំនាក់ទំនង និងសហប្រតិបត្តិការកាន់តែប្រសើរឡើងរវាងអាជ្ញាធរមូលដ្ឋានដូចជា តុលាការ នគរបាល សុខាភិបាល និងអាជ្ញាធរឃុំ/សង្កាត់ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី

# សកម្មភាពចូលរួមក្នុងគម្រោងនៅថ្នាក់ក្រោមជាតិ

សកម្មភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានបញ្ចូលការគាំទ្រលើការផ្តល់សេវាដោយផ្ទាល់ដល់រថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់គោលដៅ។ អ្នកផ្តល់សេវាថ្នាក់មូលដ្ឋាន និងអាជ្ញាធរថ្នាក់ក្រោមជាតិបានទទួលការគាំទ្រក្នុងការផ្តល់សេវាផ្លូវច្បាប់ ជម្រកសុវត្ថិភាព ការគាំទ្រផ្នែកចិត្តសង្គម សេវាសុខាភិបាល និងការព្យាបាល ព្រមទាំងជំនួយគាំទ្រផ្នែកការងារ និងអប់រំដល់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។




## រាជធានី/ខេត្តដែលមានគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី គិតចាប់ពីខែមករា ឆ្នាំ២០១៣ ដល់ ខែមិថុនា ឆ្នាំ២០១៧



# យុទ្ធនាការសាធារណៈថ្នាក់ជាតិ

រៀងរាល់ឆ្នាំមានយុទ្ធនាការសាធារណៈធំៗពីរត្រូវបានរៀបចំឡើងដើម្បីអប់រំសហគមន៍ និងកៀរគរការផ្លាស់ប្តូរសង្គមដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងកុមារី។ យុទ្ធនាការនេះរួមចំណែកដល់បេសកកម្មរបស់ក្រសួងកិច្ចការនារីក្នុងការលើកកម្ពស់សិទ្ធិស្ត្រី និងជំរុញសហគមន៍ឱ្យមានការផ្លាស់ប្តូរ។

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានគាំទ្រក្រសួងកិច្ចការនារីតាមរយៈការរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ដែលរៀបចំដោយក្រសួងកិច្ចការនារី ដៃគូអនុវត្ត និងរដ្ឋបាលថ្នាក់រាជធានី/ខេត្ត។

### ❖ យុទ្ធនាការ១៦ថ្ងៃប្រឆាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ត្រូវបានរៀបចំចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដែលជាទិវាអន្តរជាតិលុបបំបាត់អំពើហិង្សាលើស្ត្រី រហូតដល់ថ្ងៃទី១០ ខែធ្នូ ដែលជាទិវាសិទ្ធិមនុស្សអន្តរជាតិ។

- **៩** ព្រឹត្តិការណ៍សម្រាប់យុទ្ធនាការឆ្នាំ**២០១៥** “អំពើហិង្សាជាអំពើដែលមិនអាចទទួលយកបាន៖ ផ្លាស់ប្តូរការស្តីបន្ទោស”
- **៧** ព្រឹត្តិការណ៍សម្រាប់យុទ្ធនាការឆ្នាំ**២០១៦** “ចាប់ផ្តើមពីយើង”។

### ❖ ទិវាអន្តរជាតិនារី

ត្រូវបានប្រារព្ធឡើងនៅថ្ងៃទី៨ ខែមីនា ជាទិវាសាកល ដើម្បីអបអរសាទរសមិទ្ធផលសម្រេចបានផ្នែកសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងនយោបាយរបស់ស្ត្រី។

- **៥** ព្រឹត្តិការណ៍សម្រាប់យុទ្ធនាការឆ្នាំ**២០១៥** “ដំណើរឆ្ពោះទៅមុខ៖ អបអរសាទរកិច្ចព្រមព្រៀងសាកលរបស់ស្ត្រីកម្ពុជាឆ្នាំ១៩៩៥”។
- **២** ព្រឹត្តិការណ៍សម្រាប់យុទ្ធនាការឆ្នាំ**២០១៦** “ការវិនិយោគលើសមភាពយេនឌ័រ គឺជាគន្លឹះសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព”។
- **៩** ព្រឹត្តិការណ៍សម្រាប់យុទ្ធនាការឆ្នាំ**២០១៧** “ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព”។

> “អរគុណដែលបានគាំទ្រព្រឹត្តិការណ៍សហគមន៍របស់យើងខ្ញុំ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រី និងកុមារសម្រាប់អាជ្ញាធរមូលដ្ឋាន គ្រូបង្រៀន សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ ដើម្បីពង្រឹងការថែទាំសុខភាព និងវឌ្ឍនភាពនៅក្នុងកន្លែងធ្វើការ និងសហគមន៍។”
>
> អភិបាលខេត្តបាត់ដំបង

*យុទ្ធនាការទិវាអន្តរជាតិនារី ខេត្តបាត់ដំបង កម្មវិធីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា*



# វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖
# ការផ្តល់សេវា

### សកម្មភាពសំខាន់ៗរបស់គម្រោង

- អង្គការជាតិបានចូលរួមផ្តល់សេវាចម្រុះដល់ជនរងគ្រោះដោយអំពើហិង្សា
- គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានបង្កើត និងអនុវត្ត
- បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានបង្កើត និងអនុវត្ត
- ការសាកល្បង និងការធ្វើតេស្តសៀវភៅណែនាំគ្លីនិករបស់ក្រសួងសុខាភិបាល ដើម្បីគាំទ្រការអនុវត្តគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងអំពើហិង្សាលើស្ត្រី និងកុមារនៅក្នុងប្រព័ន្ធសុខាភិបាល
- ប្រព័ន្ធប្រមូលទិន្នន័យសម្រាប់ការគ្រប់គ្រងករណីត្រូវបានរៀបចំ និងអនុវត្ត
- យុទ្ធសាស្ត្រសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបានធ្វើសមាហរណកម្មក្នុងសហគមន៍ត្រូវបានអនុវត្ត និងពិនិត្យតាមដាន
- ស្ថេរភាពសេដ្ឋកិច្ច និងមុខរបរសម្រាប់ជនរងគ្រោះដែលបានធ្វើសមាហរណកម្មត្រូវបានអនុវត្ត និងពិនិត្យតាមដាន
- ការផ្តល់ប្រឹក្សាដល់គ្រួសារដើម្បីពង្រឹងទំនាក់ទំនងគ្រួសារ និងសហគមន៍សម្រាប់ជនរងគ្រោះដែលបានធ្វើសមាហរណកម្ម
- សមាជិកសហគមន៍បានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានអំពីចិត្តសង្គម និងសុខភាពផ្លូវចិត្តដើម្បីគាំទ្រជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភផ្លូវភេទ
- ក្រុមគាំទ្រការផ្តល់ប្រឹក្សា និងក្រុមជួយខ្លួនឯង ត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យប្រសើរឡើងផ្នែកសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភផ្លូវភេទ
- បុគ្គលិកថែទាំសុខភាពត្រូវបានបណ្តុះបណ្តាលអំពីការកំណត់អត្តសញ្ញាណ និងការឆ្លើយតប និងបញ្ជូនជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី
- អាជ្ញាធរឃុំ/សង្កាត់ត្រូវបានបណ្តុះបណ្តាលដើម្បីបង្កើនចំណេះដឹង និងជំនាញផ្នែកបញ្ជូន និងឆ្លើយតបទៅនឹងបញ្ហាអំពើហិង្សាលើស្ត្រីនៅមូលដ្ឋាន
- បណ្តាញអំពើហិង្សាលើស្ត្រីត្រូវបានបង្កើតឡើង ដើម្បីបង្កើតបធ្យោបាយបញ្ជូនសម្រាប់ជនរងគ្រោះនៃអំពើហិង្សា
- ក្រុមស្ត្រី និងក្រុមបុរសត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីនៅក្នុងសហគមន៍របស់ពួកគេ
- កម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានអនុវត្តសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាព ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី

រាល់សកម្មភាពផ្តល់សេវាដែលឆ្លើយតប ទៅនឹងការអនុវត្តយុទ្ធសាស្ត្រនេះ មានគោលបំណងធានាថាស្ត្រីដែលទទួលរងអំពើហិង្សាអាចទទួលបាន ឬត្រូវបានបញ្ជូនទៅរកសេវាដែលគាត់ត្រូវការ។ គោលបំណងនេះ គឺចង់លើកទឹកចិត្ត និងជំរុញឱ្យមានការឆ្លើយតបជាពហុវិស័យដែលអំណោយផលដល់ការសម្របសម្រួល និងកិច្ចសហការក្នុងការផ្តល់សេវាទាំងមូល ទោះជាសេវាដែលផ្តល់ដោយស្ថាប័នរាជរដ្ឋាភិបាល ឬស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល។ ការងារនេះត្រូវបានសម្របសម្រួលតាមរយៈការដឹកនាំ និងការគាំទ្រសមាជិកសហគមន៍ក្នុងការស្វែងយល់ និងដោះស្រាយផលប៉ះពាល់នៃអំពើហិង្សាលើជនរងគ្រោះម្នាក់ៗ គ្រួសារ និងសហគមន៍របស់ពួកគេ។

### ចំនួនជនរងគ្រោះដែលបានទទួលសេវាគាំទ្រលើការផ្តល់ប្រឹក្សា




នៅក្នុងរបាយការណ៍នេះ ការងារផ្តល់ប្រឹក្សាដែលផ្តល់ដោយដៃគូអនុវត្ត ត្រូវបានកំណត់

- ជាសេវាអន្តរាគមន៍សម្រាប់ជនរងគ្រោះម្នាក់ៗ ដូចជាការព្យាបាលផ្ទាល់ខ្លួន
- និងសេវាគាំទ្រក្រុមផ្សេងៗ ដូចជាក្រុមជួយខ្លួនឯងតាមសហគមន៍ និងកម្មវិធីលើកកម្ពស់ការយល់ដឹងរបស់សហគមន៍។

**១២,៩០៧**

ចំនួនអ្នក
ទទួលសេវា

**៩**

ចងក្រងឯកសារគោលការណ៍ណែនាំការអនុវត្ត និងសៀវភៅណែនាំការបណ្តុះបណ្តាលដែលពាក់ព័ន្ធត្រូវបានរៀបចំ អនុម័ត បោះពុម្ព និងអនុវត្តដើម្បីផ្តល់ព័ត៌មាន និងអនុសាសន៍ដល់អ្នកផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សា

**១០១**

ក្រុមជួយខ្លួនឯងត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងការរំលោភ ផ្លូវភេទដែលជួបប្រទះបញ្ហាសុខភាពផ្លូវចិត្ត និងបញ្ហាចិត្តសង្គម

**២៦៥**

ធនធានសហគមន៍ត្រូវបានបណ្តុះបណ្តាលអំពីការថែទាំផ្នែកចិត្តសង្គម និងសុខភាពផ្លូវចិត្តជាមូលដ្ឋានដើម្បីធ្វើឱ្យប្រសើរឡើងនូវការកំណត់ ការគ្រប់គ្រង និងការបញ្ជូនជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរំលោភផ្លូវភេទ

**៤៧៩**

អ្នកទទួលសេវាដែលបានធ្វើសមាហរណកម្មក្នុងគ្រួសារ និងសហគមន៍ត្រូវបានគាំទ្រដោមរយៈការប៉ាន់ប្រមាណ និងការធ្វើផែនការសុវត្ថិភាពជាទៀងទាត់

**៩២៨**

សមាជិកសហគមន៍ដែលបានចូលរួមក្នុងក្រុមជួយខ្លួនឯងដើម្បីកែលម្អរាងកាយ ចិត្តសង្គម និងដើម្បីផ្តល់នូវបណ្តាញគាំទ្រ

**២,០៣៦**

អតិថិជនទទួលបានការងារធ្វើ នឹងទទួលបានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើនស្ថេរភាពហិរញ្ញវត្ថុគ្រួសារ

## រឿងរបស់ស៊ីផាន

*ស៊ីផានមានអារម្មណ៍ឯកោណាស់។ ប្តីរបស់គាត់បានប្រើប្រាស់គ្រឿងស្រវឹង ហើយមិនបានជួយរកស៊ីចិញ្ចឹមគ្រួសារឡើយ។ គាត់គ្មានឱកាសពិភាក្សាជាមួយប្តីអំពីបញ្ហាផ្សេងៗសោះ ពីព្រោះប្តីរបស់គាត់មានចរិតឆេវឆាវ និងប្រើអំពើហិង្សាលើគាត់។ ស៊ីផានមិនអាចទ្រាំប្រឈមមុខនឹងស្ថានភាពនេះបន្តទៀតបានឡើយ ហើយក៏បានសម្រេចចិត្តសុំឱ្យប្រធានភូមិជួយ។ ប្រធានភូមិបានព្យាយាមផ្តល់យោបល់ពីរដងឱ្យប្តីរបស់គាត់ឱ្យឈប់ប្រើគ្រឿងស្រវឹង និងអំពើហិង្សា ប៉ុន្តែមិនបានសម្រេច។ បន្ទាប់មក ប្រធានភូមិក៏បានបញ្ជូនស៊ីផានទៅសុំជំនួយពីអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)។ តបតាមសំណើរបស់គាត់ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចាប់ផ្តើមជួយស៊ីផានក្នុងការដាក់ពាក្យបណ្តឹងប្តឹងលែងលះទៅតុលាការ ប៉ុន្តែប្តីរបស់គាត់បានស្នើសុំជួបជុំគ្នាវិញ ហើយបានសន្យាថា គាត់យល់ព្រមឈប់ប្រើអំពើហិង្សាលើស៊ីផាន និងកូនៗទៀតហើយ។*

> ខ្ញុំបានដកពាក្យបណ្តឹងហើយដោយមានការគាំទ្រពីអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ខ្ញុំអាចធ្វើតាមនីតិវិធីដើម្បីជួយខ្លួនឯង និងកូនៗឱ្យមានសុវត្ថិភាព។ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានផ្តល់ការអប់រំដល់ប្តីរបស់ខ្ញុំអំពីរបៀបកាត់បន្ថយអារម្មណ៍តានតឹង និងគ្រប់គ្រងកំហឹងរបស់ខ្លួន។ ដោយសារអន្តរាគមន៍របស់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ប្តីរបស់ខ្ញុំក៏បានឈប់ប្រើអំពើហិង្សា កាត់បន្ថយគ្រឿងស្រវឹង ហើយខិតខំធ្វើការដើម្បីជួយរកស៊ីចិញ្ចឹមគ្រួសារ។ សព្វថ្ងៃខ្ញុំសប្បាយចិត្តណាស់”។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
កម្មវិធីអង្គការ GIZ

***ការបណ្តុះបណ្តាលផ្នែកសុខភាពផ្លូវចិត្ត ខេត្តបាត់ដំបង កម្មវិធី TPO***



# វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការទប់ស្កាត់

## សកម្មភាពសំខាន់ៗរបស់គម្រោង

- អាជ្ញាធរឃុំ/សង្កាត់បានទទួលការបណ្តុះបណ្តាល និងការគាំទ្រក្នុងការអនុវត្តប្រព័ន្ធជូនដំណឹងអំពីគ្រឿងស្រវឹងក្នុងសហគមន៍ (CANS) ដើម្បីកាត់បន្ថយអំពើហិង្សាពាក់ព័ន្ធនឹងគ្រឿងស្រវឹង
- ឯកសារបច្ចេកទេសថ្នាក់ជាតិសម្រាប់បញ្ចូលការបណ្តុះបណ្តាល និងការអនុវត្តប្រព័ន្ធជូនដំណឹងអំពីគ្រឿងស្រវឹងក្នុងសហគមន៍ក្នុងស្ថាប័នត្រូវបានរៀបចំ និងអនុវត្ត
- គោលការណ៍ណែនាំអំពីការផ្តល់ប្រឹក្សា ដើម្បីដោះស្រាយបញ្ហាការប្រើប្រាស់បំពានគ្រឿងស្រវឹង និងអំពើហិង្សាលើដៃគូស្និទ្ធស្នាល (IPV) ត្រូវបានអនុម័ត
- ការពិនិត្យតាមដានប្រព័ន្ធផ្សព្វផ្សាយ និងការវិភាគលើការផ្សាយតាមទូរទស្សន៍អំពីអំពើហិង្សាលើស្ត្រី
- ប្រកាសក្រសួងកិច្ចការនារី និងក្រសួងព័ត៌មានស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយត្រូវបានអនុម័ត
- យុទ្ធនាការអនឡាញ និងបណ្តាញសង្គមដើម្បីលើកឡើងអំពីបញ្ហានៃការរាយការណ៍អវិជ្ជមានតាមប្រព័ន្ធផ្សព្វផ្សាយ និងអំពើហិង្សាលើដៃគូស្និទ្ធស្នាល (IPV)
- ប្រព័ន្ធបញ្ជូនទៅនគរបាល និងសេវាអ្នកឆ្លើយតបដំបូងសម្រាប់អ្នកបម្រើសេវាកំសាន្តដើម្បីផ្តល់សុវត្ថិភាពពីអំពើហិង្សាលើស្ត្រី
- កម្មវិធីមិត្តជួយមិត្តសម្រាប់អ្នកបម្រើសេវាកំសាន្តត្រូវបានអនុវត្ត
- ការបណ្តុះបណ្តាលត្រូវបានផ្តល់ដល់នគរបាលខណ្ឌ និងសង្កាត់ក្នុងរាជធានីភ្នំពេញដើម្បីឆ្លើយតបទៅនឹងសុវត្ថិភាពរបស់អ្នកបម្រើសេវាកំសាន្ត

**១៨,៣៣៧**

អ្នកចូលរួម

សកម្មភាពទប់ស្កាត់មានគោលបំណងកសាងសមត្ថភាពសមាជិក អ្នកដឹកនាំសហគមន៍ និងអ្នកផ្តល់សេវាឱ្យកាន់តែប្រសើរឡើងក្នុងការប្តេជ្ញាចិត្តចំពោះសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី រួមមានការធ្វើតេស្តចំណេះដឹង និងឥរិយាបថតាមរយៈយន្តការផ្សេងៗដូចជា ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មាន ការប្រើប្រាស់បណ្តាញសង្គមក្នុងការផ្សព្វផ្សាយសារ និងឧបករណ៍ជាវិជ្ជមានដើម្បីជួយដល់ជនល្មើសក្នុងការកែប្រែអាកប្បកិរិយារបស់ខ្លួន។

### ចំនួនអ្នកទទួលសេវាដែលបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍




នៅក្នុងរបាយការណ៍នេះ សកម្មភាពបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ដែលអនុវត្តដោយដៃគូអនុវត្តត្រូវបានកំណត់ដូចជា

- កម្មវិធីបណ្តុះបណ្តាលដែលមានរចនាសម្ព័ន្ធ
- វេទិកា និងព្រឹត្តិការណ៍សហគមន៍

ដែលមានគោលបំណងបង្កើនចំណេះដឹង ផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយាក្នុងការស្វែងយល់ និងឆ្លើយតបទៅនឹងឥទ្ធិពលនៃអំពើហិង្សាលើស្ត្រី។

> “ហេតុការណ៍គ្រោះថ្នាក់កើតឡើងជារៀងរាល់ថ្ងៃ ប៉ុន្តែបច្ចុប្បន្នយើងដឹងថា យើងអាចទូរស័ព្ទរកជំនួយពីអាជ្ញាធរ ប្រសិនបើយើងត្រូវការ។”
>
> អ្នកអប់រំមិត្ត កម្មវិធី ACTED

**៣៩** យុទ្ធនាការផ្សព្វផ្សាយក្នុងសហគមន៍ អំពីប្រព័ន្ធជូនដំណឹងស្តីពីគ្រឿងស្រវឹងនៅឃុំ សង្កាត់ (CANS) ដើម្បីលើកកម្ពស់ការយល់អំពីការប្រើប្រាស់បំពានគ្រឿងស្រវឹង

**៤៧** មេឃុំ/ចៅសង្កាត់បានទទួលការគាំទ្រក្នុងការដឹកនាំការអនុវត្តយុទ្ធនាការ ប្រព័ន្ធជូនដំណឹងស្តីពីគ្រឿងស្រវឹងនៅឃុំ សង្កាត់ (CANS) នៅក្នុងសហគមន៍របស់ខ្លួន

**៤៧** ស្ត្រីជាមេឃុំ/ចៅសង្កាត់ ជំទប់/ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់គាំទ្រ និងចូលរួមក្នុងការអនុវត្តយុទ្ធនាការ ប្រព័ន្ធជូនដំណឹងស្តីពីគ្រឿងស្រវឹងនៅឃុំ សង្កាត់ (CANS) ដើម្បីពង្រឹងការផ្តោតលើតម្រូវការរបស់ស្ត្រី និងកុមាររងគ្រោះដោយអំពើហិង្សា

**៥២** កម្មវិធីពិភាក្សាតាមវិទ្យុ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្សព្វផ្សាយអំពីការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានក្នុងការរាយការណ៍ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី

**៤១៥** អ្នកអប់រំមិត្តបានទទួលការបណ្តុះបណ្តាល និងការពិនិត្យតាមដាន ដើម្បីលើកកម្ពស់សុវត្ថិភាពផ្ទាល់ខ្លួនសម្រាប់អ្នកបម្រើសេវាកំសាន្ត

**៥៥១** យុទ្ធនាការអនឡាញ និងបណ្តាញសង្គម ដើម្បីលើកឡើងអំពីបញ្ហានៃការរាយការណ៍អវិជ្ជមានតាមប្រព័ន្ធផ្សព្វផ្សាយ និងអំពើហិង្សាលើស្ត្រី

## កត្តាជោគជ័យសំខាន់ៗ

កត្តាជោគជ័យនៃការអនុវត្តយុទ្ធនាការប្រព័ន្ធជូនដំណឹងស្តីពីគ្រឿងស្រវឹងនៅឃុំ សង្កាត់ (CANS) ដូចបានកត់សម្គាល់នៅក្នុងការវាយតម្លៃប្រព័ន្ធជូនដំណឹងអំពីគ្រឿងស្រវឹងក្នុងសហគមន៍ – របាយការណ៍ចុងក្រោយ ឆ្នាំ២០១៦

- ការប្រើប្រាស់បំពានគ្រឿងស្រវឹង និងការកាត់បន្ថយអំពើហិង្សាលើដៃគូស្និទ្ធស្នាល IPV – មានការព្រមព្រៀងជាទូទៅថា ការប្រើប្រាស់បំពានគ្រឿងស្រវឹង និង IPV បានថយចុះ។
- ការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃការប្រើបំពានគ្រឿងស្រវឹង និង IPV – មានការយល់ដឹងកម្រិតខ្ពស់អំពីផលប៉ះពាល់នៃការប្រើបំពានគ្រឿងស្រវឹង រួមទាំងទំនាក់ទំនងរបស់វាជាមួយ IPV។
- ការផ្លាស់ប្តូរអាកប្បកិរិយាទាក់ទងនឹងការអនុវត្តយុទ្ធនាការ CANS– មានការផ្លាស់ប្តូរច្រើនផ្អែកលើយុទ្ធនាការ CANS ឧទាហរណ៍ លែងមានការលក់ដូរគ្រឿងស្រវឹងតាមសាលារៀន វត្តអារាម ការលក់គ្រឿងស្រវឹងឱ្យកុមារមិនគ្រប់អាយុត្រូវបានកាត់បន្ថយ។
- ប្រសិទ្ធភាពយុទ្ធនាការ CANS និង ‘ដីកា’ – សហគមន៍ជឿថា ‘ដីកា’ មានប្រសិទ្ធភាព ក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរ។ CANS និង ‘ដីកា’ ផ្តល់នូវកម្មវិធីគោលនយោបាយជាផ្លូវការទប់ស្កាត់នឹងការផ្សព្វផ្សាយគ្រឿងស្រវឹង ឬ IPV ឬសម្រាប់ផ្តល់ការអប់រំ។

*“ដីកាស្តីពីការគ្រប់គ្រងគ្រឿងស្រវឹង គឺជាវិធានការច្បាប់នៅថ្នាក់ឃុំ/សង្កាត់ ដែលកំណត់លើការលក់ ការប្រើប្រាស់ និងការផ្សព្វផ្សាយគ្រឿងស្រវឹង។ ការអនុម័ត និងអនុវត្តដីកា ជាសិទ្ធិអំណាចរបស់មេឃុំ/ចៅសង្កាត់”។*

“មុនពេលអនុវត្តយុទ្ធនាការ CANS ខ្ញុំបានផ្តល់ប្រឹក្សាដល់ប្រជាពលរដ្ឋចំនួន១០ គ្រួសារ ដែលមានបញ្ហាពាក់ព័ន្ធនឹងគ្រឿងស្រវឹង និងអំពើហិង្សាក្នុងគ្រួសារ។ សព្វថ្ងៃនេះ ខ្ញុំផ្តល់ប្រឹក្សាដល់ប្រជាពលរដ្ឋតែមួយគ្រួសារប៉ុណ្ណោះ”។

អនុប្រធានភូមិ នៅឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ កម្មវិធី TAF

*យុទ្ធនាការសហគមន៍ទប់ស្កាត់គ្រឿងស្រវឹង មជ្ឈមណ្ឌលប្រជាជនដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ខេត្តស្វាយរៀង កម្មវិធី TAF*



# វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការការពារផ្នែកច្បាប់

## សកម្មភាពសំខាន់ៗរបស់គម្រោង

- ការគាំទ្របច្ចេកទេសត្រូវបានផ្តល់ឱ្យអាជ្ញាធរយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់រាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ ដើម្បីផ្តល់ជំនួយក្នុងការដោះស្រាយនីតិវិធីករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៃអំពើហិង្សាក្នុងគ្រួសារ។
- ការផ្តល់ប្រឹក្សា និងការគាំទ្រ បច្ចេកទេសត្រូវបានផ្តល់ឱ្យគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារថ្នាក់រាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌសម្រាប់ការបញ្ជូនករណី និងផ្តល់យោបល់ផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- បណ្តាញតស៊ូមតិរបស់កុមារត្រូវបានអនុវត្ត និងគាំទ្រ ក្នុងការលើកកម្ពស់ការយល់ដឹង និងការឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ
- សេវាផ្នែកច្បាប់ត្រូវបានផ្តល់ដល់ស្ត្រី និងកុមារជាជនរងគ្រោះដោយអំពើហិង្សា
- មន្ត្រីនគរបាលយុត្តិធម៌ (JPO) និងភ្នាក់ងារនគរបាលយុត្តិធម៌ (JPA) បានទទួលការបណ្តុះបណ្តាល កសាងសមត្ថភាពក្នុងការផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយអំពើហិង្សាស្របតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥
- គោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់ការបណ្តុះបណ្តាល JPO/JPA និងការផ្សព្វផ្សាយត្រូវបានធ្វើបច្ចុប្បន្នភាព
- គោលការណ៍ណែនាំស្តីពីការសម្រុះសម្រួល (កំពុងរៀបចំ) ដើម្បីឆ្លើយតបទៅនឹងបញ្ហាអំពើហិង្សាលើស្ត្រី កំពុងស្ថិតក្រោមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
- សៀវភៅណែនាំអំពីនីតិវិធីតុលាការ (កំពុងរៀបចំ) ដែលនឹងត្រូវប្រើប្រាស់ដោយអ្នកប្រកបវិជ្ជាជីវៈច្បាប់ ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី កំពុងស្ថិតក្រោមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

**២,៩៣៨**

អ្នកចូលរួម

សកម្មភាពពាក់ព័ន្ធនឹងការការពារផ្នែកច្បាប់ ដែលបានអនុវត្តនៅក្នុងយុទ្ធសាស្ត្រសំខាន់នេះ បានផ្តោតលើសកម្មភាពអភិវឌ្ឍសមត្ថភាពជាក់លាក់ ដូចជាការពិនិត្យតាមដាន ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មានសម្រាប់មន្ត្រីផ្នែកច្បាប់ រាប់ទាំងវិធីសាស្ត្រដែលមានគោលបំណងពង្រឹងយន្តការច្បាប់នៅថ្នាក់ក្រោមជាតិដែលមានស្រាប់ ដើម្បីកែលម្អ និងបង្កើនការទទួលបានសេវាផ្នែកច្បាប់សម្រាប់ជនរងគ្រោះ និងបង្កើនសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីផ្នែកច្បាប់ដែលតម្រូវឱ្យឆ្លើយតបទៅនឹងជនរងគ្រោះដោយអំពើហិង្សា។

### ចំនួនអ្នកទទួលបានសេវាផ្នែកច្បាប់




នៅក្នុងរបាយការណ៍នេះ សកម្មភាពឆ្លើយតបនឹងផ្នែកច្បាប់ដែលផ្តល់ដោយដៃគូអនុវត្តត្រូវបានកំណត់ដូចជា

- សកម្មភាពកសាងសមត្ថភាពសម្រាប់អាជ្ញាធរ មន្ត្រីយុត្តិធម៌ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងជនរងគ្រោះដោយអំពើហិង្សា និង
- សេវាផ្នែកច្បាប់ដែលផ្តល់ដោយមេធាវី ដើម្បីជួយដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងការដោះស្រាយបញ្ហានៅតុលាការ ទាំងករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

> “ព័ត៌មានជាច្រើនអំពីអំពើហិង្សាក្នុងគ្រួសារអាចងាយរកបាន ហើយការយល់ដឹងក៏មានការកើនឡើងផងដែរ។ មានការរីកចម្រើន (វឌ្ឍនភាព) លើការដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែមានចំណុចជាច្រើនដែលត្រូវកែលម្អ។”
>
> អធិការរងនគរបាលស្រុកបាណន់ ខេត្តបាត់ដំបង កម្មវិធី LAC។

**៧**

បណ្តាញតស៊ូមតិកុមារដើម្បីបង្កើនការយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ និងរបៀបចាត់វិធានការបង្ការ និងសុវត្ថិភាព

**៤៧**

កិច្ចប្រជុំបណ្តាញយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានរៀបចំ ដើម្បីពង្រឹងតួនាទីរបស់អ្នកពាក់ព័ន្ធនៃប្រព័ន្ធយុត្តិធម៌ក្នុងការផ្តល់សេវាយុត្តិធម៌ដល់ជនរងគ្រោះដោយអំពើហិង្សា

**៥១**

កម្មវិធីបណ្តុះបណ្តាលត្រូវបានផ្តល់ដល់មន្ត្រីនគរបាលយុត្តិធម៌ / ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី (JPO/JPA) និងជនបង្គោលស្ត្រីថ្នាក់ស្រុក ដើម្បីគាំទ្រពួកគេក្នុងការអនុវត្តតួនាទីរបស់ខ្លួនស្របតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥

**៦៨**

កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តបានទទួលការគាំទ្រលើការបញ្ជូនករណី និងការប្រឹក្សាយោបល់ផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយៃអំពើហិង្សា

**២៣៨**

កិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុកបានទទួលការគាំទ្រលើការបញ្ជូនករណី និងការប្រឹក្សាយោបលផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយអំពើហិង្សា

**១,១៩១**

ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទបានទទួលប្រឹក្សាផ្នែកច្បាប់ និងភាពជាតំណាងផ្លូវច្បាប់ក្នុងការដាក់ពាក្យប្តឹងតាមរយៈប្រព័ន្ធយុត្តិធម៌ផ្លូវការ

> "សម្រាប់ខ្ញុំ ការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌បានជួយឱ្យខ្ញុំបំពេញការងារ និងដោះស្រាយបញ្ហារបស់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារកាន់តែងាយស្រួល។ មន្ត្រីនគរបាលយុត្តិធម៌អាចរកយុត្តិធម៌ជូនស្ត្រីបាន។"
>
> *សក្ខីកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ខេត្តសៀមរាប កម្មវិធីអង្គការ GIZ*

## កត្តាជោគជ័យសំខាន់ៗ

កត្តាជោគជ័យនៃបណ្តាញយុត្តិធម៌ព្រហ្មទណ្ឌដូចបានរាយការណ៍ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ឆ្នាំ២០១៦

- តុលាការដោះស្រាយសំណុំរឿងលឿនជាងមុនក្នុងការឆ្លើយតបទៅនឹងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- ការសម្របសម្រួលសេវាបានប្រសើរជាងមុនសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- កិច្ចសហការកាន់តែរឹងមាំរវាងអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ និងស្ថាប័នរដ្ឋាភិបាល.
- មានការយល់ដឹងកាន់ច្បាស់អំពីច្បាប់ និងកាតព្វកិច្ចរបស់នគរបាល និងតុលាការ។
- ករណីព្រហ្មទណ្ឌដែលបានរៀបចំដោយនគរបាលយុត្តិធម៌មានការរៀបចំបានត្រឹមត្រូវ និងត្រូវបានរៀបចំតាមនីតិវិធីបញ្ជូនទៅតុលាការទាន់ពេលវេលា។

***អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រាជធានីភ្នំពេញ កម្មវិធី ACTED***



# វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖
# ការគាំទ្រស្ថាប័ន និងសម្របសម្រួល

### សកម្មភាពសំខាន់ៗរបស់គម្រោង

- ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-១៨ ត្រូវបានបង្កើតឡើង និងអនុវត្ត
- ការគាំទ្រផ្នែកបច្ចេកទេសត្រូវបានផ្តល់ជូនក្រសួងកិច្ចការនារី ក្នុងការបង្កើត ពិនិត្យវាយតម្លៃ និងតាមដានការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី
- ក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើតឡើង និងទទួលបានការគាំទ្របច្ចេកទេស ដើម្បីកែលម្អសហប្រតិបត្តិការ និងការសម្របសម្រួលអន្តរវិស័យ
- ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារីនៅកម្ពុជា៖ ជាយុទ្ធសាស្ត្រដើម្បីអនុវត្តចំណុចអាទិភាពនៃការងារទប់ស្កាត់នៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី
- គំរូសម្រាប់ការវិភាគថ្លៃចំណាយលើការសម្របសម្រួលសេវា និងការបញ្ជូនជនរងគ្រោះដោយអំពើហិង្សា ត្រូវបានអនុវត្តនៅក្នុងខេត្តគោលដៅ
- បណ្តាញមន្ត្រីវ័យក្មេងរបស់ក្រសួងកិច្ចការនារីត្រូវបានបង្កើតឡើង និងគាំទ្រលើការបណ្តុះបណ្តាលផ្នែកសារគមនាគមន៍
- ការបង្កើតបណ្តាញអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង/ស្រុកក្រោមរចនាសម្ព័ន្ធរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត និងក្រុង/ស្រុក




**ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-២០១៨ ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤**

**បានផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥**

សកម្មភាពគាំទ្រស្ថាប័ន និងការសម្របសម្រួល ដែលត្រូវបានអនុវត្តក្នុងយុទ្ធសាស្ត្រនេះ មានគោលបំណងកែលម្អ និងបង្កើនការសម្របសម្រួល និងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីទាមទារឱ្យអ្នកពាក់ព័ន្ធពីវិស័យផ្សេងៗជាច្រើននៅក្នុងរាជរដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍ និងអ្នកផ្តល់សេវាចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី។ ការអភិវឌ្ឍសមត្ថភាព និងការសម្របសម្រួលស្ថាប័នរួមចំណែកដល់ការឆ្លើយតបចម្រុះលើការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការផ្តល់សេវាដល់ជនរងគ្រោះ។

### បណ្តាញសំខាន់ៗ

បណ្តាញមួយចំនួនត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់ក្រសួងកិច្ចការនារីក្នុងការដឹកនាំ និងសម្របសម្រួលការឆ្លើយតបអន្តរវិស័យក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងពង្រឹងបណ្តាញគាំទ្រ និងការសម្របសម្រួលរបស់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើហិង្សា។

**១** ក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ដោយសេចក្តីសម្រេចរបស់លោកជំទាវវេជ្ជបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារីដើម្បីពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-២០១៨។ សមាជិកក្រុមការងារនេះរួមមាន

- ដៃគូអភិវឌ្ឍន៍ចំនួន១០
- ក្រសួងស្ថាប័នពាក់ព័ន្ធចំនួន១៥
- សមាជិកអង្គការសង្គមស៊ីវិលចំនួន៣០

**៧** បណ្តាញអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្តត្រូវបានបង្កើតឡើង ដោយមានការអនុម័តជាផ្លូវការដោយអភិបាលនៃគណៈអភិបាលខេត្ត ដើម្បីសម្របសម្រួលការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**៨** បណ្តាញអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ស្រុកត្រូវបានបង្កើតឡើង ដោយមានការអនុម័តជាផ្លូវការដោយអភិបាលស្រុក ដើម្បីសម្របសម្រួលការឆ្លើយតបទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**៨០** សមាជិកបណ្តាញមន្ត្រីវ័យក្មេងត្រូវបានបង្កើតឡើង ដើម្បីជួយគាំទ្រដល់ការធ្វើកំណែទម្រង់ស្ថាប័នរបស់ក្រសួងកិច្ចការនារី

**១៩៤** គណៈកម្មាធិការគ្រប់គ្រងបានចាប់ផ្តើមដំណើរការចាប់ពីខែមករា ឆ្នាំ២០១៥ ដល់ ខែធ្នូ ឆ្នាំ២០១៦ ដែលមានស្ត្រីជាតំណាងរបស់ខ្លួននៅក្នុងតួនាទីធ្វើសេចក្តីសម្រេច និងជាអ្នកដឹកនាំ។

# ការបណ្តុះបណ្តាល៖

កម្មវិធីបណ្តុះបណ្តាលត្រូវបានផ្តល់ដល់អាជ្ញាធរមូលដ្ឋាន មន្ត្រីផ្នែកច្បាប់ និងអ្នកផ្តល់សេវាថែទាំសុខភាព ដើម្បីបញ្ចូលការឆ្លើយតបយេនឌ័រទៅនឹងបញ្ហានៃអំពើហិង្សាលើស្ត្រី។ កម្មវិធីបណ្តុះបណ្តាលគឺសំដៅលើការកសាងសមត្ថភាពសម្រាប់អ្នកឆ្លើយតបជួរមុខ និងដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងអំពីផលប៉ះពាលនៃអំពើហិង្សាលើបុគ្គលម្នាក់ៗ គ្រួសារ និងសហគមន៍។

### ក្រាហ្វិកខាងក្រោមបង្ហាញពីការចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពចន្លោះពីខែមករា ឆ្នាំ២០១៣ ដល់ ខែកក្កដា ឆ្នាំ២០១៧

**មន្ត្រីផ្នែកច្បាប់ និងមន្ត្រីយុត្តិធម៌**

រួមមាននគរបាល មន្ត្រីតុលាការ និងមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួងកិច្ចការនារី




**អ្នកផ្តល់សេវាថែទាំសុខភាព**

រួមមានអ្នកផ្តល់សេវាសុខភាពថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ និងគ្រូពេទ្យនៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព




**អាជ្ញាធរមូលដ្ឋាន**

រួមមានមេឃុំ ចៅសង្កាត់ និងមេភូមិ អនុប្រធានភូមិ និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងជនបង្គោលស្ត្រី




**អ្នកចូលរួមកម្មវិធីបណ្តុះបណ្តាលសរុប**




> អ្នកជំងឺបានមកទទួលសេវាពីខ្ញុំជាច្រើនដង។ គាត់មានរបួស និងស្នាមជាំនៅលើមុខ ប៉ុន្តែខ្ញុំមិនដែលបានដឹងថា គាត់ជាជនរងគ្រោះដោយអំពើហិង្សាទេ។ ខ្ញុំគិតថា ស្ត្រីជាជនរងគ្រោះខ្លាស់ខ្ញុំ បើសិនជាខ្ញុំសួរនាំគាត់ពីអំពើហិង្សា។ ប៉ុន្តែ បន្ទាប់ពីបានចូលរៀនវគ្គបណ្តុះបណ្តាល ខ្ញុំបានសួរនាំគាត់ ហើយគាត់បានប្រាប់ខ្ញុំថា គាត់បានទទួលរងអំពើហិង្សាពីប្តីរបស់គាត់។

ឆ្មបមន្ទីរពេទ្យបង្អែក កម្មវិធីអង្គការឃែរ (CARE program)

# វឌ្ឍនភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖
# ការសិក្សាស្រាវជ្រាវ និងភស្តុតាង

គម្រោង បានគាំទ្រសកម្មភាពស្រាវជ្រាវជាច្រើន ដើម្បីឈ្វេងយល់ឱ្យបានច្បាស់អំពីបរិបទកម្ពុជា កំណត់និន្នាការនៃអំពើហិង្សាក្នុងពេលកន្លងមក និងផ្តល់ជម្រើសពីរបៀបប្រើប្រាស់ទិន្នន័យនេះ ក្នុងការរួមចំណែកចំពោះការរៀបចំគោលនយោបាយទប់ស្កាត់អំពើហិង្សា។

- ការប៉ាន់ប្រមាណពីតម្រូវការយេនឌ័រនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤៖ សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ជំពូកទី៧ ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី http://bit.ly/mowaCGA2014en
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី១៖ ការប្រើប្រាស់បំពានគ្រឿងស្រវឹងនៅកម្ពុជា http://asiafoundation.org/publications/pdf/1584
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី២៖ ការមើលឃើញតាមប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា http://asiafoundation.org/publications/pdf/1585
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី៣៖ ការធ្លាប់ជួបប្រទះអំពើហិង្សាតាំងពីកុមារភាពនៅកម្ពុជា http://asiafoundation.org/publications/pdf/1586
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី៤៖ ការទទួលបានការអប់រំនៅកម្ពុជា http://asiafoundation.org/publications/pdf/1587
- ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS)៖ http://countryoffice.unfpa.org/cambodia/drive/2014CDHSKIR_2-20-2015.pdf
- ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាពស្ត្រី និងបទពិសោធន៍ក្នុងជីវិតនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៥៖ http://www.wpro.who.int/mediacentre/releases/2015/vaw_full-en.pdf
- បញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា៖ របាយការណ៍លើកទី១ស្តីពី បច្ចុប្បន្នភាពគម្រោង ឆ្នាំ២០១៥ http://dfat.gov.au/about-us/publications/Documents/cambodia-ending-violence-against-women-program-summary-achievements-2014-15.PDF
- ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ ឆ្នាំ២០១៤-២០១៨ http://cambodia.unfpa.org/publications/national-action-plan-prevent-violence-against-women-2014-2018
- របាយការណ៍វឌ្ឍនៈភាពលើទី២នៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា ឆ្នាំ២០១៦ http://dfat.gov.au/about-us/publications/Pages/cambodia-ending-violence-against-women-second-apr-2016-khmer.aspx
- របាយការណ៍ស្តីពីការវិភាគទិន្នន័យលើបទពិសោធន៍របស់ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សាផ្សេងៗ ឆ្នាំ២០១៦ http://cambodia.unfpa.org/en/publications/secondary-analysis-womens-experience-domestic-violence-and-other-forms-violence
- សហគ្រាសផលិតស្រានៅកម្ពុជា៖ ការសិក្សាអំពីពន្ធដារ បទបញ្ញត្តិ ការចែកចាយ និងការសេពគ្រឿងស្រវឹង http://asiafoundation.org/publication/alcohol-industry-cambodia-report/





















# ករណីសិក្សា

## រឿងរបស់ចន្ទី កម្មវិធីអង្គការហាហ្កា

ចន្ទីបានទទួលរងការឈឺចាប់ដោយសារការរំលោភបំពានក្នុងគ្រួសារពីសំណាក់ប្ដីកំណាចរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ។ មួយថ្ងៃៗ ប្ដីរបស់នាងតែងតែផឹកស្រា ហើយបញ្ចេញចរិតកាចសាហាវ និងវ៉ៃដំចន្ទីជារឿយៗ។ ជាញឹកញាប់ ចន្ទីតែងតែរត់ទៅពួនក្រោយផ្ទះ ដើម្បីគេចឱ្យផុតពីការវាយដំដ៏សាហាវនេះ។ ក្រោយមក នាងក៏បានរាយការណ៍អំពីការវាយដំប្រាប់ប្រធានភូមិ និងនគរបាល។ ប្រធានភូមិ និងនគរបាលក៏បានកោះហៅប្ដីរបស់ចន្ទីឱ្យចុះកិច្ចសន្យាបញ្ជាក់ថា គាត់ឈប់វាយធ្វើបាបចន្ទីទៀតហើយ ប៉ុន្តែការសន្យានេះពុំមានប្រសិទ្ធភាពបានយូរឡើយ។ ពីរបីខែក្រោយមក អំពើហិង្សាក៏បានផ្ទុះឡើងជាថ្មី។ ដោយស៊ូទ្រាំនឹងការវាយដំលែងបាន ចន្ទីបានលែងលះប្ដីរបស់ខ្លួន ហើយក៏បានចុះចេញពីគ្រួសារ។

បន្ទាប់ពីការលែងលះគ្នា ម្ដាយក្មេកចន្ទីក៏បានលក់ផ្ទះរួមរបស់គ្រួសារ ហើយបានផ្ដល់ប្រាក់មួយចំនួនឱ្យចន្ទី។ ការលក់ផ្ទះនេះបានធ្វើឡើងនៅពេលដែលចន្ទីបានសម្រេចចិត្តទៅរស់នៅផ្ទះយាយរបស់នាង។ ចន្ទីក៏ត្រូវបានបញ្ជូនទៅអង្គការហាហ្កា ហើយអង្គការនេះក៏បានផ្ដល់ការគាំទ្រដល់នាងក្នុងការធ្វើសមាហរណកម្មនាងទៅរស់នៅជាមួយកូនប្រុសខ្លួនក្នុងសហគមន៍វិញ។ អង្គការហាហ្កាបានផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសេវាគាំទ្រការងារសង្គម ដើម្បីជួយចន្ទី និងកូនប្រុសរបស់នាងរស់នៅប្រកបដោយសេចក្ដីសុខសុវត្ថិភាពនៅផ្ទះយាយរបស់នាង។

> ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការហាហ្កាដែលបានផ្ដល់ការគាំទ្រសព្វបែបយ៉ាងដើម្បីជួយលើកទឹកចិត្តខ្ញុំ។ ជំនួយហិរញ្ញវត្ថុជារឿងមួយ ប៉ុន្តែអង្គការហាហ្កាបានធ្វើឱ្យខ្ញុំយល់ពីតម្លៃរបស់ខ្លួន និងចេះឱ្យតម្លៃខ្លួនឯង។ ដូច្នេះ ខ្ញុំសូមអរគុណ អ្វីដែលសំខាន់បំផុត គឺអង្គការហាហ្កាបានផ្ដល់ឱកាសឱ្យខ្ញុំផ្លាស់ប្ដូរជីវិតរបស់ខ្លួន និងមើលឃើញពីក្ដីសង្ឃឹមសម្រាប់អនាគត។

## រឿងរបស់លោកស្រី ឡី សំណាង កម្មវិធីអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO program)

នៅក្នុងឆ្នាំ១៩៩៩ សំណាង និងប្ដីរបស់គាត់មានកូនប្រុសម្នាក់។ មួយឆ្នាំក្រោយមក កូននោះក៏បានស្លាប់ដោយសារជំងឺ។ នៅក្នុងឆ្នាំនោះ ប្ដីរបស់នាងបានចាប់ផ្ដើមប្រើប្រាស់គ្រឿងស្រវឹង ហើយបានវាយតប់គ្នាជាមួយនាងយ៉ាងខ្លាំងស្ទើរតែរៀងរាល់ថ្ងៃ។ ប្ដីនាងបានបំផ្លាញរបស់របរក្នុងផ្ទះ និងបានប្រើអំពើហិង្សាលើរាងកាយកូនស្រីរបស់ខ្លួន។ ការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្តបានធ្វើឱ្យកូនស្រីភ័យខ្លាចយ៉ាងខ្លាំង។ លោកស្រីសំណាងគិតថា គ្មាននរណាម្នាក់អាចជួយគាត់បានទេ។ គាត់បានចាប់ផ្ដើមឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត។ គាត់មានអារម្មណ៍ថា គ្មានអ្វីជាទីពឹងទៀតទេ ហើយបានព្យាយាមធ្វើអត្តឃាត។ អាជ្ញាធរមូលដ្ឋានបានជំរុញឱ្យគាត់ចូលរួមជាមួយក្រុមជួយខ្លួនឯង។ អង្គការ TPO ក៏បានផ្ដល់ប្រឹក្សាជាលក្ខណៈបុគ្គលដល់គាត់។ គាត់បានចាប់ផ្ដើមគិតថាជីវិតមានន័យឡើងវិញ។

គាត់បានសម្ដែងអារម្មណ៍សប្បាយ និងមានមោទនភាព។ “ខ្ញុំរំភើប និងរីករាយយ៉ាងខ្លាំងដែលអង្គការ TPO បានជួយខ្ញុំ។ ខ្ញុំមានសុភមង្គលអាចញញឹម សើច និងមើលឃើញពិភពលោកខាងក្រៅច្បាស់ និងមិនឃើញភាពខ្មៅងងឹតដូចមុនទៀតទេ។ ហើយខ្ញុំអាចនិយាយបានថា៖

> អង្គការ TPO ប្រៀបដូចជាប្រេងកាត ហើយខ្ញុំប្រៀបដូចជាចង្កៀងដែលគ្មានភ្លើងបំភ្លឺ។ ចង្កៀងអាចមានភ្លើងភ្លឺវិញ ដោយសារប្រេងកាត។ នេះមានន័យថា ខ្ញុំបានស្ថិតក្នុងភាពងងឹតគ្មានពន្លឺ និងគិតថា ជីវិតរស់នៅដូចជាស្លាប់ ប៉ុន្តែអង្គការ TPO បានមកជួយផ្ដល់ជីវិតថ្មីឱ្យខ្ញុំ

វគ្គបណ្ដុះបណ្ដាលភ្នាក់ងារនគរបាលយុត្តិធម៌ ខេត្តកំពង់ធំ កម្មវិធី GIZ



វគ្គបណ្ដុះបណ្ដាលស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ខេត្តប៉ៃលិន កម្មវិធី LAC



វគ្គបណ្ដុះបណ្ដាលស្ដីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិស័យសុខាភិបាល កម្មវិធី UNFPA



សមាជិកក្រុមជួយខ្លួនឯង ខេត្តបាត់ដំបង កម្មវិធី TPO



ការពិភាក្សារបស់សហគមន៍អំពីយុទ្ធនាការ CANS នៃមជ្ឈមណ្ឌលភីឌីភី ខេត្តស្វាយរៀង កម្មវិធី TAF



**ក្រសួងកិច្ចការនារី**

ផ្លូវទ្រុងមាន់  ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារលេខ៖ +៨៥៥ (០) ២៣ ៨៨០ ៧៣៧
Email:mwa@online.com.khwww.mowa.gov.kh
www.facebook.com/mowa.gov.kh

**ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា**

១៦ ផ្លូវរដ្ឋសភា ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ៖ +៨៥៥ (០) ២៣ ២១៣ ៤៧០
ទូរសារលេខ៖ ៨៥៥ (០) ២៣ ២១៣ ៤១៣